ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ............ សហវ ............

ថ្ងៃ ............ ខែ ............ ឆ្នាំ ម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ............ ឆ្នាំ ២០២៦

**សូមជម្រាបជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ៖** ករណីការស្នើសុំអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា ពង្រីកវិសាលភាពសាលារៀនជំនាន់ថ្មីចំនួន ១ បន្ថែម សម្រាប់ការអនុវត្តចាប់ពីឆ្នាំសិក្សា ២០២៥-២០២៦ តទៅ។

**យោង៖** លិខិតលេខ ៧២២ អយក.ហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២៥ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា ពង្រីកវិសាលភាពសាលារៀនជំនាន់ថ្មី ចំនួន ១ បន្ថែម គឺវិទ្យាល័យពោធិ៍សាត់ សម្រាប់ការអនុវត្តចាប់ពីឆ្នាំសិក្សា ២០២៥-២០២៦ តទៅ។ ទន្ទឹមនេះ, ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំផែនការរួមនៃការពង្រីកវិសាលភាពសាលារៀនជំនាន់ថ្មី សម្រាប់ខេត្តដទៃៗទៀត ដែលពុំទាន់មានសាលារៀនជំនាន់ថ្មី សម្រាប់ឆ្នាំសិក្សាបន្តបន្ទាប់ ដើម្បីឱ្យស្របតាមការសម្រេចដ៏ខ្ពង់ខ្ពស់ជាគោលការណ៍ពីប្រមុខរាជរដ្ឋាភិបាល និងម្យ៉ាងទៀត ដើម្បីឱ្យមានផែនការច្បាស់លាស់ សម្រាប់ការគិតគូរថវិកាគាំទ្រ តាមលទ្ធភាពថវិកាជាក់ស្តែងប្រចាំឆ្នាំនីមួយៗ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ជ្រាប និងចាត់ចែងតាមការគួរ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ទទួលនូវគោរវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

លេខ: ............ អយក.ចល
**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃ ............ ខែ ............ ឆ្នាំ ............ ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ............ ឆ្នាំ២០២៦
**តប. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**អគ្គលេខាធិការ**

**នេព តិយៀរិទ្ធ**